# យោបល់របស់សាធារណៈជន ក្នុងអង្គប្រជុំសាធារណៈរបស់គណកម្មាធិការកែទម្រង់សាលារៀន

## ការណែនាំអំពីការចុះឈ្មោះដើម្បីឡើងនិយាយ

ដើម្បីចុះឈ្មោះឡើងនិយាយនៅពេលប្រជុំធម្មតា ឬនៅពេលប្រជុំពិសេស សូមទូរស័ព្ទមក ការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និងសហគមន៍ លេខ ២១៥-៤០០-៤១៨០ កុំឲ្យហួសម៉ោង ៤:៣០ ល្ងាច នៃថ្ងៃធ្វើការ មុនថ្ងៃប្រជុំ ដែលលោកអ្នកចង់លើកយោបល់ឲ្យគណៈកម្មាធិការកែទម្រង់សាលារៀន។

- វិធីសម្រាប់ការលើកយោបល់ឲ្យគណកម្មាធិការកែទម្រង់សាលារៀន មានដូចតទៅ៖
    - បុគ្គលទាំងអស់ត្រូវតែចុះឈ្មោះរបស់ខ្លួនឯង ហើយមិនអាចចុះឈ្មោះឲ្យអ្នកដទៃបានទេ។
    - បុគ្គលដែលតំណាងឲ្យអង្គការណាមួយ ត្រូវតែប្រាប់ឈ្មោះអង្គការនោះ នៅពេលចុះឈ្មោះ ហើយអង្គការមួយមិនអាចមានអ្នកតំណាងចុះឈ្មោះឡើងនិយាយលើសពីម្នាក់បានទេ នៅក្នុងប្រជុំមួយ។
    - បុគ្គលទាំងអស់ត្រូវតែផ្តល់ ឈ្មោះ អាស័យដ្ឋាន លេខទូរស័ព្ទពេលថ្ងៃ និង ប្រធានបទ ដែលពួកគេនឹងលើកឡើងឲ្យគណៈកម្មាធិការកែទម្រង់សាលារៀន។
    - បុគ្គលទាំងអស់ត្រូវតែយកយោបល់ដែលបានសរសេរប្រាំពីរច្បាប់មកកាន់ទីប្រជុំ។
    - បុគ្គលទាំងអស់មិនអាចនិយាយលើសពីបីនាទីបានទេ។
    - គេមិនអនុញ្ញាតឲ្យបុគ្គលទាំងអស់លើកពីបញ្ហាដូចគ្នាលើសពីប្រាំមួយនាក់បានទេ ប៉ុន្តែពួកគេអាចទុកយោបល់របស់ពួកគេដែលបានសរសេរ ឲ្យគណៈកម្មាធិការកែទម្រង់សាលារៀនពិនិត្យមើល។
    - គេនឹងដកបុគ្គលទាំងឡាយណាចេញពីលេខរៀង បើសិនជាពួកគេព្យាយាមបញ្ចេញយោបល់ ឬ រិះគន់ អំពីការប្រព្រឹត្តិ ឬទង្វើរបស់បុគ្គលិក នៃ ក្រសួងអប់រំណាម្នាក់ ហើយគេនឹងបញ្ជូនពួកគេឲ្យទៅផ្តល់យោបល់ ប្រាប់ដល់រដ្ឋបាលនៃក្រសួងអប់រំដែលទទួលបន្ទុក។
    - គេនឹងដកបុគ្គលទាំងឡាយណាចេញពីលេខរៀង បើសិនជាពួកគេព្យាយាមបញ្ចេញយោបល់ពីរឿងផ្ទាល់ខ្លួនរបស់បុគ្គលដទៃទៀត ទោះជាបុគ្គលនោះនៅ ឬមិននៅទីនោះក៏ដោយ ហើយ
    - គេនឹងដកបុគ្គលទាំងឡាយណាចេញពីលេខរៀង ហើយសុំឲ្យចាកចេញពីអង្គប្រជុំ បើសិនជាពួកគេប្រើពាក្យថោកទាប ឬ អាសអាភាស។

ជាបន្ថែមទៀត លោកអ្នកអាចប្រគល់យោបល់របស់លោកអ្នកតាមការសរសេរ ទៅឲ្យគណៈកម្មាធិការកែទម្រង់សាលារៀន ដោយផ្ញើ ឬ ប្រគល់ឲ្យដោយផ្ទាល់ទៅការិយាល័យគណៈកម្មាធិការកែទម្រង់សាលារៀន ដែលស្ថិតនៅអាស័យដ្ឋានលេខ 440 North Broad Street, Suite 101, Philadelphia, PA 19130។

### ការកែសម្រួលនូវការអនុវត្តនាពេលបច្ចុប្បន្នដែលទាក់ទងនឹងលំដាប់នៃអ្នកឡើងនិយាយ៖

គណៈកម្មាធិការកែទម្រង់សាលារៀននឹងអនុវត្តពិធីការថ្មី ដោយយោងទៅលើគោលការណ៍ពីរ។ ទីមួយ ជាការសំខាន់ចំពោះក្រុមអ្នកឡើងនិយាយដែលមានប្រធានបទដូចគ្នា ឬស្រដៀងៗគ្នា ក្នុងអង្គប្រជុំ (Action Meetings) ដើម្បីឲ្យគណៈកម្មាធិការកែទម្រង់សាលារៀនមានលទ្ធភាពយល់ដឹងកាន់តែទូលំទូលាយអំពីប្រធានបទទនោះ។ ទីពីរ គណៈកម្មាធិការកែទម្រង់សាលារៀនចង់ជំរុញឲ្យមានយោបល់ និងប្រធានបទថ្មី នៅក្នុងអង្គប្រជុំ។

ចាប់ផ្តើមនៅ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ គណៈកម្មាធិការកែទម្រង់សាលារៀន (SRC) នឹងអនុម័តនូវការផ្លាស់ប្តូរទៅនឹងលំដាប់ដែលអ្នកឡើងនិយាយនៅក្នុងអង្គប្រជុំ របស់គណកម្មាធិការកែទម្រង់សាលារៀន ដូចតទៅ៖

- គេនឹងបន្តផ្តល់អាទិភាពដល់សិស្សដែលជាអ្នកឡើងនិយាយ ហើយតាមធម្មតាត្រូវឡើងនិយាយមុនគេ។
- អ្នកឡើងនិយាយដទៃទៀតត្រូវដាក់ជាក្រុមតាមប្រធានបទ ដោយយោងទៅតាមលំដាប់នៃការចុះឈ្មោះប្រធានបទរបស់ពួកគេ។
- អ្នកឡើងនិយាយដែលមិនបាននិយាយនៅក្នុងអង្គប្រជុំលើកមុន នឹងត្រូវអនុញ្ញាតឲ្យនិយាយមុនគេ ក្នុងក្រុមដែលមានប្រធានបទដូចគ្នា ហើយបន្ទាប់គឺអ្នកឡើងនិយាយដែលមានឱកាសនិយាយនៅក្នុងអង្គប្រជុំលើកមុន
- អ្នកឡើងនិយាយអំពីសេចក្តីសម្រេចផ្សេងៗ នឹងមិនត្រូវបានគេផ្តល់អាទិភាពឲ្យទៀតទេ ដោយសារអ្នកនិយាយទាំងនោះមានឱកាសឡើងនិយាយមុនពេលបោះឆ្នោត អំពីសេចក្តីសម្រេចទាំងនេះរួចហើយ។ អ្នកឡើងនិយាយទាំងនោះ ត្រូវដាក់ក្នុងក្រុមតាមប្រធានបទ និងពេលវេលាដែលពួកគេបានចុះឈ្មោះ ជាមួយអ្នកឡើងនិយាយដទៃទៀត។